**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១០

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារ
## ជំរុញការប្រមូលចំណូលពី ការជួលទ្រព្យសម្បត្តិរដ្ឋ និងឯកជនភាវូបនីយកម្ម

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ១៣៨អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារជំរុញកៀរគរចំណូលពី ការជួលទ្រព្យសម្បត្តិរដ្ឋ និងឯកជនភាវូបនីយកម្មដែលមាន សមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ខេវី្វ ទិស្សុត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ម៉ាន សាហ៊ីប** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤- លោក **នេត មុន្នី** | ប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៥- លោក **អ៊ុំ ឈាង** | ប្រធាន នាយកដ្ឋានឃ្លាំងបេឡា និងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៦- លោក **ប៊ុន បុណ្ណារិទ្ធ** | អនុប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៧- លោក **សាន់ សារោ** | អនុប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៨- លោក **អោម ចន** | អនុប្រធាន នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩- លោក **នួន សំបូរ** | ប្រធាន ការិយល័យអចលនទ្រព្យ | សមាជិក |
| ១០- លោក **គឹម កែវមុនីរ័ត្ន** | ជំនួយការ អគ្គលេខាធិការ | សមាជិក |
| ១១- លោក **ម៉ម រិទ្ធី** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១២- លោក **មុំ ថាវណ្ណ** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៣- លោក **សុក ការណេត** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៤- លោក **គីត ម៉ូរ៉ាស៊ី** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | លេខាធិការ |

**ប្រការ២:** ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចតទៅៈ

- ជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការជំរុញតឹងទារបំណុល និងកៀរគរចំណូលពីការជួល ទ្រព្យសម្បត្តិរដ្ឋ និងឯកជនភាវូបនីយកម្ម ។
- ពិនិត្យតាមដាន និងដាក់ចេញវិធានការជាប្រចាំ ដើម្បីជម្រុញតឹងទារបំណុល និងគៀងគរចំណូល ។

- ពិនិត្យទិដ្ឋភាពផ្លូវច្បាប់ ដើម្បីរកលទ្ធភាពសើរើ ឬលប់ កិច្ចសន្យាជួល កិច្ចសន្យាផ្ទេរឯកជនភាវូបនីយកម្ម ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ ឬធ្វើអោយរដ្ឋខាតបង់ចំណូល ។
- រាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំសេចក្តីសម្រេច និងការណែនាំបន្ថែម ។

**ប្រការ៣:** អនុប្រធាន សមាជិក ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ ។

**ប្រការ៤:** រាល់លិខិតបទដ្ឋានដែលផ្ទុយពីការប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គាធិការ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវសហការ និងអនុវត្តការងារអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

***កន្លែងទទួល:***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*